-Reçu le 5-7-51-
1/169
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# ចិត្តសហាហញារី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ



Janvier

ឆ្នាំទី២ – មករា លេខ ១

ព.ស. ២៤៩៣-គ.ស. ១៩៥១

ពរឆ្នាំ ១៩៥១

មិត្តសាលាបាលី　　ក្នុងឆ្នាំថ្មីសូមជូនពរ

អ្នកមានបានសាទរ　　មូលមិត្តភក្តិស្ម័គ្រស្មាគម ៗ

សូមកបសុខសួស្តី　　ជីវិតថ្មីល្អឧត្តម

រុងរឿងថ្កើងស័ក្តិសម　　ជាពូជពង្សពុទ្ធសាស្នពិត ៗ

វៀរចាកបាបកម្ម　　កុំគិតផ្សាំផ្សំក្នុងចិត្ត

អំពើណាសុចរិត　　ទើបប្រព្រឹត្តគិតថែងចាត់ ៗ

ស្រស់ស្រាយផ្សាយមេត្តា　　កាយវាចាត្រូវដុសខាត់

ប្រឹងប្រែងប្រតិបត្តិ　　ប្រុងប្រយ័ត្នក្នុងសីលទាន ៗ

ការនារៀនរាល់ថ្ងៃ　　គុណវត្តត្រែជាប្រធាន

រាំងកុំបំពាន　　ច្បាប់ព្រះពុទ្ធវិសុទ្ធថ្លា ៗ

សូមគុណកែវទាំងបី　　ផ្សាយរស្មីទូទិសា

គ្រប់ដែននៃលោកា　　ឲ្យភ្លឺស្វាងទាំងថ្ងៃយប់ ៗ

យល់ត្រូវមានសាមគ្គី　　ចេញចាកទីងងឹតឈប់

លែងច្បាំងតតាំងទប់　　ឈប់អាឃាតព្យាបាទគ្នា ៗ

បានក្តីសុខក្សេមក្សាន្ត　　សត្វភូមិឋានសព្វៗគ្រា

ប្រកបដោយជោគជា　　ជានិរន្តរ៍តទៅហើយ ៗ

មិត្តសាលាបាលី

# វិចារណកថា

ថ្ងៃនឹងយប់ដែលកន្លងទៅ មិនមែនកន្លងទៅទទេឯងៗឡើយ គឺតែងស៊ីលេបអាយុជីវិតសត្វទៅផង ។ សព្វសត្វតែងប្រហែសធ្វេសបណ្តែតបណ្តោយខ្លួនគិតដល់សេចក្តីពិតនេះឯង, វិលចុះវិលឡើង មិនទាន់ទាំងបានធ្វើករណីយកិច្ចជាប្រយោជន៍អ្វីផង ស្រាប់តែដាច់ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី, ជីវិតរបស់ខ្លួនក៏រលត់បាត់បង់ទៅអស់មួយឆ្នាំ; ហេតុនេះ ទើបព្រះដ៏មានបុណ្យទ្រង់ត្រាស់រំលឹកថា "សេចក្តីប្រហែស ជាផ្លូវនៃសេចក្តីស្លាប់ ជនអ្នកប្រហែសទុកជាស្លាប់" ។

សេចក្តីប្រហែសធ្វេស សំដៅយកត្រង់ការភ្លាំងភ្លេចស្មារតី ឬការបណ្តែតបណ្តោយបន្ទើបន្ទង់រង់ចាំស្អែក ។ ធម៌នេះជាកំពូលនៃអកុសលធម៌ទាំងឡាយ ។ សេចក្តីអាក្រក់មន្ទិលសៅហ្មងគ្រប់ចំពូក តែងប្រជុំចុះក្នុងសេចក្តីប្រហែសនេះតែម្យ៉ាង គឺថាធម៌បែកខាងអកុសលទាំងអស់មានសេចក្តីប្រហែសជាមូល ឬជាមេក្រឡាញធំបំផុត ។ អរិយជនទាំងឡាយមានព្រះពុទ្ធជាដើម តែងស្អប់ខ្ពើមហើយតិះដៀលនូវសេចក្តីប្រហែសធ្វេសដោយអនេកបរិយាយ ព្រោះមេអកុសលនេះ ញុំាងសត្វឲ្យធ្លាក់ចុះក្នុងហាយនភាពច្រើនប្រការគឺ:

- នាំឲ្យខាតខូចទ្រព្យសម្បត្តិ-យសស័ក្តិ-បំណះវិជ្ជា នឹងនាំឲ្យសាបរលាបថយថោកងើបមុខមិនរួចក្នុងបច្ចុប្បន្ន, ដូចកុកចាស់ដែលជ្រុះស្លាបអស់កេហើរទៅកាន់ទីណាពុំរួច ។

– នាំឲ្យខាតប្រយោជន៍ផ្សេងៗ, នាំឲ្យជាអ្នកឡ្វេឡ្វាក្រោយគេ ឲ្យជាអ្នកទាល់ច្រក, ឲ្យជាអ្នកយឺតដើរមិនទាន់កាលសម័យ ដូចជាសេះខ្វកជើងឬសេះប្រគ្រីវ ផាយមិនទាន់គេ ។

– បិទបាំងមិនឲ្យមានប្រាជ្ញា, មិនឲ្យសំឡឹងមើលលោកតាមសេចក្តីពិតបាន, ឲ្យទទួលតែសភាវការណ៍តាមដែលសង្កេតឃើញ, ឲ្យជាប់ស្អិតក្នុងធម៌ជាគូ, ឲ្យជាប់ក្នុងសំសារវដ្ត ដូចកង្កែបអើតកនៅតែក្នុងអណ្តូង ។

– ឲ្យជាខ្ញុំនៃតណ្ហា, តាមតែតណ្ហាញាក់ឲ្យជ្រែកមមកទៅក្នុងទីណាក៏បាន, ដូចគ្នានឹងដំរីដែលនៅក្នុងកណ្តាប់ដៃទម័កមានកង្វេរដ៏មុះមុត ឬក៏ដូចគ្នានឹងសំណាត់ឈើដែលអណ្តែតតាមក្រសែទឹកនឹងតាមសន្ទុះខ្យល់ ។

ដូច្នេះ, សេចក្តីប្រហែសធ្វេស ជាហេតុនៃសេចក្តីវិនាសអន្តរាយគ្រប់យ៉ាង, ធ្វើមនុស្សដែលកំពុងមានដង្ហើមចេញចូលឲ្យដូចជាមនុស្សស្លាប់ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្ដី ជាភិក្ខុនីក្ដី ជាឧបាសកក្ដី ជាឧបាសិកាក្ដី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីគោរពក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន និងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

## ទាំងអស់មានរសតែមួយ

មហាសមុទ្រមានរសតែមួយគឺរសប្រៃយ៉ាងណាមិញ, ធម៌ដែលព្រះសម្ពុទ្ធបានសំដែងហើយ ក៏មានរសតែមួយគឺវិមុត្តិរសយ៉ាងនោះដែរ ។

អ្វីដែលហៅថាវិមុត្តិរស? ពាក្យនេះញែកចេញជាពីរផ្នែក គឺ "**វិមុត្តិ**" និង "**រស**" ។ **វិមុត្តិ** "ការរួចស្រឡះឬចេញផុត (ចាកសំសារទុក្ខ)= ព្រះនិព្វាន" **រស** មានអត្ថច្រើនប្រការ តែក្នុងទីនេះ សំដៅយក "រសជាតិ, ដំណើរសុខស្រួល, សេចក្ដីត្រជាក់ត្រជុំ, ផ្អែមល្ហែម..." ។ ដូច្នេះ, **វិមុត្តិរស** បានសេចក្ដីថា រសគឺសេចក្ដីរួចស្រឡះចាកសំសារទុក្ខ ឬរសគឺព្រះនិព្វាន ។

សេចក្ដីទុក្ខលំបាក ជារណ្ដៅលាមកមួយដែលពពួកសត្វតែងខ្ពើមរអើមជាទីបំផុត តែកម្រនឹងចៀសវាងបាន ។ ព្រះពុទ្ធជាម្ចាស់បាន

ប្រកាសរឿយៗ អំពីរឿងទុក្ខនេះ ដោយអាងហេតុផលជាអនេកបរិយាយ ដើម្បីឲ្យសព្វសត្វយល់ច្បាស់ប្រាកដនូវដើមកំណើតនៃសេចក្ដីទុក្ខ ពោលគឺមន្ទិលសៅហ្មងឬអកុសល ។

ឯអកុសលនេះ មានមូល (ឫសគល់) ៣ គឺ លោភៈ សេចក្ដីលោភជាប់ស្អិតស្អិតក្ដាំងក្នុងអារម្មណ៍, ទោសៈ សេចក្ដីប្រទុស្ដប្រទៀតឃោរឃៅ, មោហៈ សេចក្ដីងងឹតងងល់មិនយល់ការពិត ។ សត្វទាំងឡាយ មិនអាចចូលទៅក្រេបផឹកនូវវិមុត្តិរសបាន ព្រោះទាក់ទើសនឹងឫសអកុសលទាំង ៣ យ៉ាងនេះឯង ។ ដូច្នេះ ការគាស់រំលើងនូវបាបធម៌នេះចោលបាន ឈ្មោះថានាំឲ្យបានរួចជ្រះស្រឡះពីអកុសលសព្វចំពូក, ការបានជ្រះស្រឡះពីអកុសលនោះឯងជាហេតុញ៉ាំងទុក្ខទាំងឡាយមានជាតិទុក្ខជាអាទិ៍ឲ្យសាបសូន្យទៅ ។

រីឯឧបាយសម្រាប់កំចាត់បង់អកុសលមូលទាំងនោះ គឺ :

១ — ទាន សម្រាប់កំចាត់បង់នូវ លោភៈ

២ — សីល សម្រាប់កំចាត់បង់នូវ ទោសៈ

៣ — ភាវនា សម្រាប់កំចាត់បង់នូវ មោហៈ ។

ព្រះធម៌គឺពុទ្ធវចនៈទាំងអស់ ដែលព្រះសាស្ដាបានប្រកាសហើយក្នុងទីសព្វអន្លើ តាំងពីថ្ងៃដែលទ្រង់បានត្រាស់ហូតមកទល់នឹងថ្ងៃចូល

បរិនិព្វាន   សូម្បីមានច្រើនបែបច្រើនប្រភេទ   ដោយលៃទៅតាមអធ្យាស្រ័យសត្វក៏ពិតមែន,   តែគង់រួមចូលក្នុងធម៌ទាំង ៣ គឺ ទាន, សីល, ភាវនា នេះឯង ដែលជាធម៌មាននាទីខាងដុតបំផ្លាញឬរំលើងចោលនូវអកុសលមូលជាដើមកំណើតនៃសេចក្ដីទុក្ខ   ជាប្រយោជន៍ទីង បានជួបប្រទះនូវវិមុត្តិរសតែមួយក្នុងទីបំផុត ។

ទីក្រុងមួយដ៏ស្រស់បំព្រង ជាទីគួរពិតពិលរមិលមើលនៃបណ្ដាជនទូទៅ   មានផ្លូវខ្វាត់ខ្វែងជាច្រើនចូលមកពីខេត្តក្រៅគ្រប់ទិសតូច-ធំ ។ ជនទាំងឡាយមានបំណងចូលមកមើលទីក្រុងនោះ   ចង់ដើរតាមផ្លូវណាមួយក៏អាចចូលដល់ទីក្រុងបានដូចគ្នា   ថ្វីបើផ្លូវមានច្រើនដូច្នោះ   ព្រោះផ្លូវទាំងនោះនាំចូលទៅកាន់ទីក្រុងតែមួយក្នុងទីបំផុត,   សេចក្ដីនេះយ៉ាងណាមិញ; ធម៌របស់ព្រះពុទ្ធក៏យ៉ាងនោះដែរ ។

ដូច្នេះ,   ធម៌ទាំងឡាយនោះទោះបីមានច្រើនដូចម្ដេចក៏មានរសជាតិតែមួយគឺ **វិមុត្តិរស** ។

ព្រោះហេតុអ្វីបានជាព្រះពុទ្ធអង្គទ្រង់បញ្ជាក់ដូច្នេះ?   ព្រោះការពារកុំឲ្យសត្វយល់ដោយភាន់ច្រឡំថា   ឧបាយទាំងឡាយដែលទ្រង់បានចង្អុលបង្ហាញហើយនោះ   នាំសត្វអ្នកប្រតិបត្តិទៅកាន់វត្ថុបំណងផ្សេងៗគ្នា   គឺប្រយោជន៍ដើម្បីឲ្យសត្វយល់ជាក់ប្រាកដនូវវត្ថុបំណងនោះឯង ។

ក៉យ-ប៊ុក

## នមស្សការព្រះពុទ្ធ ១០ ព្រះអង្គក្នុងអនាគត

## ឧកញ៉ាភក្តីសាទេព កែ-នេត្រ រៀបរៀង

*ឃុនឧត្តមប្រីជា ចាប-ពិន ពិនិត្យកែ*

មេត្តេយ្យោ នាគរុក្ខោ ច  រាមពុទ្ធោបិ ចន្ទនំ
ចម្មកោ នាគរុក្ខោ  សាលរុក្ខោ ធម្មសាមី ។
នារទោ ចន្ទនរុក្ខោ  រំសីមុនិ ច បិប្ផលិ
ទេវទេវោ ច ចម្បកោ  ចន្ទនរុក្ខោ ច នាគលិ ។
នរសីហោ ច និគ្រោធោ  តិស្សពុទ្ធោ សុមង្គលោ
នាគរុក្ខោ ឯតេ ទស  រុក្ខា ពោធី ភវិស្សន្តិ ។
អនាគតេ ឥមេ ទស  សម្ពុទ្ធេ យោ នមេ កាយ-
ទសសតសហស្សានិ  និរយំ សោ ន គច្ឆតិ ។

ខ្ញុំសូមបង្គំ គុណព្រះបរម សម្មាសម្ពុទ្ធ ទាំង ១០ ព្រះអង្គ ក្នុង អនាគត សូមរួចចាកផុត ទុក្ខសោកភ័យា ។

ទី ១ - ព្រះសិរីអារ្យមេត្រី ច្រើនបុណ្យបារមី ខ្ពស់លើលោកា ព្រះជន្មព្រះអង្គ ប្រាំបីម៉ឺនវស្សា កំពស់ហាត្ថា ប៉ែតសិបប្រាំបី ដើមខ្លឹមជាពោ- ធិព្រឹក្សសេដ្ឋា ចាំងថៃងរង្សី ផុះរ័តនបល្ល័ង្ក ទីនាំងសួស្តី ស្តេចគង់សេរី ត្រាស់ធម្មទេសនា ។

ទី ២ – ព្រះកម្ពស់ខ្ពស់ ពូជពោធិវង្ស ត្រាស់ឡើងកាលណា
ព្រះជន្មព្រះអង្គ ប្រាំបួនម៉ឺនវស្សា ជាព្រះសម្មា· សម្ពុទ្ធរ័តន៍ ៗ
ព្រះកាយព្រះអង្គ ខ្ពង់ខ្ពស់លន់ ដល់ប៉ែតសិបហត្ថ ដើមចន្ទន៍ក្រហម
ជាពោធិ៍ឡើងក្លាត់ ក្លិនក្លែបផ្សាយផាត់ ពេយរុះដល់ដី ៗ ផុះរតនបល្ល័ង្ក
ជាព្រះទីនាំង ថ្វាយព្រះជិនស្រី ស្ដេចគង់សោយសុខ វិមុត្តិប្រពៃ
ត្រាស់ដឹងធម៌ថ្លៃ ឥតមានបន្ទោះ ៗ

ទី ៣ – ព្រះបាទបសេន- ទិកោសលេន្ទ្រ ទ្រង់ត្រាស់ឡើងស្មោះ
ទ្រង់ព្រះនាមថា ព្រះធម្មកជាផ្ដោះ ព្រះជន្មអង្គនោះ ប្រាំបីម៉ឺនវស្សា ៗ
ព្រះកាយព្រះអង្គ ខ្ពង់ខ្ពស់ត្រយង់ ជប់ប្រាំមួយហត្ថ ដើមខ្លឹងជាពោ-
ធិព្រឹក្សសាខា ស្មោមស្លឹកបុប្ផា ក្រអូបអប់អង្គ ៗ ផុះរតនបល្ល័ង្ក
ក្លិនផ្ចេកបិទបាំង ព្រះរង្សីសុរិយង្ក ស្ដេចគង់ក្សេមក្សាន្ត ឥតព្រួយ
ព្រះអង្គ ដកបដល់ទ្រង់ ជាមហាមុនី ៗ

ទី ៤ – មារាធិរាជ បានត្រាស់អង្គអាច ជាព្រះសាមី ព្រះជន្ម
មួយសែន ព្រះកាយជិនស្រី ខ្ពង់ខ្ពស់បារមី ដល់ប៉ែតសិបហត្ថ ៗ
ដើមកាំងក្នុជា ពោធិព្រឹក្សមហា ដូចស្វេតច្ឆត្រ មានផ្ការុះពេយ ថ្វាយ
ព្រះមហាសត្វ បល្ល័ង្កល្អក្ដាត់ ផុះក្រោមរុក្ខជាត ៗ ថ្វាយព្រះអរហំ
ជាព្រះទីនាំង ទៃទទិព្វស្អាងស្អាត ដូចកែវព្រោងព្រាយ ពណ្ណរាយ
លើសខ្នាត ព្រះត្រៃលោកនាថ ទ្រង់ត្រាស់ទេសនា ៗ

ទី ៥– កហុអស្សុរិទ្ធ ជាវង្សទេវិទ្ធ មានរិទ្ធិចេស្តា បានត្រាស់
រួចស្រេច ទ្រង់ព្រះនាមថា នារទសាស្តា មានបុណ្យបារមី ៗ
ព្រះជន្មព្រះអង្គ មួយម៉ឺនឆ្នាំទ្រង់ កាយកបវង្សី ខ្ពស់ម្ភៃហត្ថ នៃព្រះ
ជិនស្រី ដើមចន្ទន៍ល្អក្រៃ ជាពោធិ៍ព្រឹក្ស ៗ ផុះរ័តន៍បល្ល័ង្ក ឡើង
ជាទីនាំង ស្តេចគង់ឥតក្ងឹក ទេវតាណាន់ណែន ម៉ឺនសែនបីអធិក
ព្រះអង្គរំលឹក បុព្វកសនា ៗ

ទី ៦– សោណព្រាហ្មណ៍ទ្រង់ ប្រសើរខ្ពស់ខ្ពង់ បានត្រាស់
ឡើងជា ព្រះវង្សមុនី មានព្រះជន្មា ប្រាំពាន់វស្សា ហុកសិបហត្ថ
គត់ ៗ ដើមលៀបជាពោ ធិព្រឹក្សសោភា ថ្វាយអង្គពុទ្ធរ័តន៍ ផុះ
រ័តន៍បល្ល័ង្ក ទីនាំងពេនព័ទ្ធ ភ្លឺផ្លេកប្រភាត់ ដូចកែវចរណៃ ៗ

ទី ៧– សុកព្រាហ្មណ៍អង្គ កសាងយូរលង់ ប្រឹនអសង្ខេយ្យ
ទ្រង់ត្រាស់ព្រះនាម ទេវទេពថ្កើងក្រៃ ព្រះជន្មចមត្រៃ ប្រាំម៉ឺនវស្សា ៗ
ព្រះកាយព្រះអង្គ ខ្ពង់ខ្ពស់ទត្រុង្គ ប៉ែតសិបហត្ថា ដើមចម្ប៉ាស ផ្កា
ល្អបុប្ផា ជាពោធិ៍សាខា ក្រអូបពេកក្រៃ ៗ ផុះរ័តន៍បល្ល័ង្ក ឡើងជា
ទីនាំង ដូចកែវចរណៃ ស្តេចគង់ខ្ពង់ខ្ពស់ លើសលុបព្រឹក្សព្រៃ
អស់ទេពសួគ៌ថ្ងៃ គង់គាល់គារវៈ ៗ

ទី ៨– ព្រះតោទេយ្យព្រាហ្មណ៍ ទ្រង់ត្រាស់ព្រះនាម ព្រះនរសីហៈ
ព្រះជន្មព្រះអង្គ ប៉ែតសិបឆ្នាំជាក់ ទ្រង់ជាពំនាក់ សព្វសត្វនានា ៗ

ព្រះកាយព្រះអង្គ ខ្ពង់ខ្ពស់ត្រចង់ ហុកសិបហត្ថា ប្រទៀងជាពោ-ធិព្រឹក្សថ្លៃថ្លា ផ្សាយក្លិនបុប្ផា អប់អង្គព្រះកាយ ។ ផុះរតនបល្ល័ង្ក ឡើងជាទីនាំង ស្តេចគង់ឆើតឆាយ ឥតមានអំពល់ ក្នុងព្រះអង្គកាយ ទេវតាទាំងឡាយ គាល់ព្រះបរមត្រៃ ។

ទី៩ – នាឡាគិរី ពូជពង្សពោធិ៍ សាងមកយូរក្រៃ ប្រាថ្នានាំសត្វ ឆ្លងកាត់ផលស័យ ពោលគឺកពត្រៃ ដល់ត្រើយអមតៈ ។ ត្រាស់ស្រេចព្រះអង្គ ព្រះនាមបមពង្ស ជាព្រះតិស្សៈ ព្រះជន្មព្រះអង្គ ប្រាំម៉ឺនឆ្នាំជាក់ ជាទីពំនាក់ សព្វមនុស្សទេព្តា ។ ព្រះកាយព្រះអង្គ ប៉ែតសិបហត្ថទ្រង់ គួរទស្សនា ដើមព្រៃជាពោ- ធិព្រឹក្សថ្លៃថ្លា ស្កោមស្ងួតសាខា ថ្វាយព្រះទ្រង់ញាណ ។ កើតរតនបល្ល័ង្ក ថ្វាយជាទីនាំង ស្តេចគង់ក្រៀមក្សាន្ត រំលឹកធម៌ថ្លៃ ញាណពេញយកល្យាណ ទេវតាប្រមាណ ច្រើនអសង្ខេយ្យា ។ គង់គាល់ព្រះអង្គ ស្តាប់ធម៌ស្តេចទ្រង់ សំដែងទេសនា ឲ្យបានជាផ្លូវ ទៅកាន់ព្រះមហា- និព្វានសុខា ឥតកើតស្លាប់ផង ។

ទី១០ – ធ័របាលិលេយ្យ ស្តេចមានញាណពេញ សាងច្រើនកប្បហោង ប្រាថ្នាបានត្រាស់ ទេសនាចំឡង នាំអស់សត្វផង អនេកអន័គ្យ ។ ស្តេចត្រាស់ឡើងក្តុល់ នាមព្រះសុមង្គល ជាអង្គឯកអគ្គ ព្រះជន្មព្រះអង្គ មួយសែនឆ្នាំជាក់ ព្រះកាយគបល័ក្ខណ៍

ល្អឥតផ្ទឹមបាន ៗ ខ្ពស់ហុកសិបហត្ថ ប្រសើរពេកក្កាត់ ព្រះអនាវរ-ណញ្ញាណ ដើមខ្លឹងជាពោ- ធិព្រឹក្សយោនយាន ស្លឹកផ្កាជាហាន ចាំងសែងសុរិយា ៗ ផ្ការីកនៅនិត្យ ថ្វាយព្រះបពិត្រ អប់ព្រះកាយា ផុះរ័តន៍បល្ល័ង្ក ទីនាំងពេជ្រថ្វា ថ្វាយព្រះសាស្តា ជាគ្រូបម្រង ៗ

វីជនឯណា មានចិត្តជ្រះថ្លា ក្រៃពេកកន្លង បានថ្វាយបង្គំ នូវព្រះពុទ្ធផង ទាំងផប់នេះហោង ដូចបានរៀបរាប់ ៗ ជននោះបានផល ប្រិនឥតផ្ទឹមផល់ ប្រសើរគ្រគាប់ មិនធ្លាក់នរក អស់សែននៃកប្ប . ជាមនុស្សមានកំពូ ក៏សនាខ្ពស់ខ្ពង់ ៗ

ខ្ញុំសូមនមស្ការ ព្រះសាស្តាចារ្យ ទាំង ១០ ព្រះអង្គ សូមឲ្យខ្ញុំបាន ឋានធំឧត្តុង្គ បានសុខយូរលង់ គឺនិព្វានហោង ៗ

# អបរិហានីយធម្មសូត្រ

សម័យមួយព្រះដ៏មានព្រះភាគ ស្ដេចគង់នៅនាភ្នំគិជ្ឈកូដជិតក្រុងរាជគ្រឹះ, គង់ទីនោះព្រះអង្គទ្រង់ត្រាស់ហៅពួកភិក្ខុឲ្យមកជួបជុំហើយ ទ្រង់មានព្រះពុទ្ធដីកាថា: ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវអបរិហានីយធម៌ឲ្យអ្នកទាំងឡាយស្ដាប់ឥឡូវនេះ ។ ពួកភិក្ខុក៏ទទួលព្រះពុទ្ធដីកាថា: ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងថា: ម្នាលភិក្ខុទាំងឡាយ អបរិហានីយធម៌មាន ៧ ប្រការ ។ ៧ ប្រការតើអ្វីខ្លះ? រួចហើយទ្រង់ត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា:

អភិណ្ហសន្និបាតា ភវិស្សន្តិ សន្និបាតពហុលា ភិក្ខុត្រូវខំស្ដាប់ប្រជុំគ្នារឿយៗ ត្រូវមានការប្រជុំច្រើន ។

សមគ្គា សន្និបតិស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ សមគ្គា សង្ឃករណីយានិ ករិស្សន្តិ ភិក្ខុកាលនឹងចូលកាន់ទីប្រជុំក៏ព្រមគ្នា កាលលើកលែងប្រជុំក៏ព្រមគ្នា នឹងព្រមគ្នាជួយធ្វើកិច្ចការដែលសង្ឃត្រូវធ្វើ ។

អបញ្ញត្តំ ន បញ្ញបេស្សន្តិ បញ្ញត្តំ ន សមុច្ឆិស្សន្តិ ភិក្ខុមិនបញ្ញត្តថែមសិក្ខាបទដែលទ្រង់មិនបានបញ្ញត្ត នឹងមិនបន្ថយសិក្ខាបទដែលទ្រង់បានបញ្ញត្តហើយ គឺប្រតិបត្តិតាមតែសិក្ខាបទដែលមានមកហើយនោះ ។

យេ តេ ភិក្ខុ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិនាយកា តេ សក្ការិស្សន្តិ គរុការិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ *ភិក្ខុឯណាជាថេរៈដ៏ដឹងរាត្រីមុនបួសយូរហើយ ជាសង្ឃបិតា សង្ឃបរិនាយក ពួកភិក្ខុចី ត្រូវធ្វើសក្ការៈគោរពរាប់អាន បូជាចំពោះព្រះថេរៈនោះ ។*

ឧប្បន្នាយ តណ្ហាយ បោនោព្ភវិកាយ នោ វសំ គច្ឆិស្សន្តិ *ភិក្ខុមិនត្រូវលុះអំណាចតណ្ហាដែលនាំឲ្យកើតក្នុងភពតទៅទៀត ។*

អរញ្ញកេសុ សេនាសនេសុ សាបេក្ខា ភវិស្សន្តិ *ភិក្ខុត្រូវមានសេចក្តីអាល័យក្នុងសេនាសនស្ងាត់ ។*

បច្ចត្តញ្ញេវ សតឹ ឧបដ្ឋបេស្សន្តិ កិន្តិ អនាគតា បេសលា សព្រហ្មចារី អាគច្ឆេយ្យុំ *ភិក្ខុត្រូវតាំងសតិចំពោះខ្លួនថា: ធ្វើដូចម្តេចហ្ន៎ សព្រហ្មចារី អ្នកមានសីលជាទីស្រឡាញ់ដែលមិនទាន់បានមក (ក្នុងទីនេះ) ក៏សូមឲ្យនិមន្តមក ដែលបានមកហើយ ក៏សូមឲ្យនៅជាសុខចុះ ។*

វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ *ធម៌តាំង៧ប្រការនេះ មាននៅដរាបណា សេចក្តីចំរើនក្នុងធម្មវិន័យក៏មាននៅដរាបនោះ មិនមែនជាសេចក្តីវិនាសសាបសូន្យឡើយ ។*

លុះព្រះសម្ពុទ្ធទ្រង់សំដែងសូត្រនេះចប់ហើយ ពួកភិក្ខុទាំងឡាយក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគនោះ ៗ

សេចក្តីអធិប្បាយខ្លីៗ តាមលំអានគន្ធអដ្ឋកថា:

១ — ត្រង់ដែលថា ភិក្ខុត្រូវប្រជុំគ្នារឿយៗ ត្រូវមានការប្រជុំច្រើននោះ មានសេចក្តីថា ប្រសិនបើភិក្ខុមិនបានប្រជុំនឹងខានបានស្តាប់ប្រវត្តិអំពីទិសទាំង ៤ សូម្បីវត្តឯណោះៗ មានភិក្ខុបាបលាមកធ្វើឧបោសថ-បវារណាឲ្យរឹករមិនត្រូវតាមធម៌ ខ្វះធ្វើទូតកម្ម-វេជ្ជកម្ម ខ្វះធ្វើកុលទូសក-កម្ម ព្រោះហេតុតែការចិញ្ចឹមជីវិត ភិក្ខុទាំងនោះធ្វើសាសនាឲ្យអាប់ឱនយ៉ាងនេះក៏ព្រះសង្ឃពុំបានដឹង ព្រោះហេតុនោះការប្រជុំនេះជាគុណនឹងបានស្តាប់ប្រវត្តិនោះៗ រួចហើយនឹងបញ្ជូនគណសង្ឃឲ្យទៅរម្ងាប់អធិ-ករណ៍ដូចមានក្នុងខាងលើនោះឯង ៗ

២— ភិក្ខុកាលចូលទៅកាន់ទីប្រជុំក៏ព្រមគ្នា លើកលែងប្រជុំក៏ព្រមគ្នា មានសេចក្តីថា: ការងាររបស់សង្ឃ បើព្រះសង្ឃកំណត់ពេលជួបជុំដោយសំឡេងស្គរ-រគាំង ចួង ជាគតិកាដើម្បីនឹងបោសជំរះលានពោធិ-ព្រឹក្ស លានចេតិយ ពេញឧបោសថ ធ្វើវត្តតូច-ធំ ឬព្យាបាលភិក្ខុឈឺជាដើម ភិក្ខុត្រូវមកជួបជុំប្រញាប់ប្រញាល់តាមកិច្ចនោះៗ មិនត្រូវបណ្តោះបណ្តៃថា អាត្មាអញរវល់គក់ចីវរ ដុតបាត្រធ្វើនវកម្មដូច្នេះបានឡើយ ត្រូវតែផ្អាកការងាររបស់ខ្លួនៗហើយក្រោកប្រញាប់ប្រញាល់

ដោយតាំងចិត្តថា: អាត្មាអញទៅមុនៗព្រមគ្នាតែម្តង ដូច្នេះឈ្មោះថា ចូលកាន់ទីប្រជុំក៏ព្រមគ្នា លុះរួចកិច្ចនោះហើយលើកលែងប្រជុំក៏លើកលែងព្រមគ្នា ៗ មួយវិញទៀតភិក្ខុកាលបានឮដំណឹងថា វត្តឯណោះៗ មានភិក្ខុបាបលាមកធ្វើឧបោសថបវារណាឲ្យវិកល ធ្វើទូតកម្ម-វេជ្ជកម្ម ជាអំពើមិនគប្បី ក៏និយាយថាអាត្មាអញនឹងទៅធ្វើសេចក្តីសង្គ្រោះភិក្ខុទាំងនោះ ហើយក៏ក្រោកព្រមគ្នាដូច្នេះ ឈ្មោះថាក្រោកចេញចាកទីប្រជុំក៏ព្រមគ្នា ទាំងនេវាសិកភិក្ខុអ្នកនៅក្នុងវត្ត បើបានឃើញអាគន្តុកភិក្ខុមកដល់ហើយ ក៏ត្រូវធ្វើវត្តតាមបែបអាវាសិកវត្ត បើឃើញអាគន្តុកភិក្ខុមានត្រៃចីវរនឹងបាត្រចាស់គ្រាំគ្រាប្រើប្រាស់មិនបាន ខ្លួនអាចនឹងស្វែងរកបាន ក៏គួរស្វែងរកមកប្រគេន បើឃើញអាគន្តុកភិក្ខុមានអាពាធ ក៏គួរនឹងស្វែងរកថ្នាំមកជួយព្យាបាល ឬក៏នាំយកទៅកាន់ទីកន្លែងរបស់ខ្លួន បើឃើញគាត់ដួលក៏គួរជួយគ្រាហ៍លើកឡើង នាំទៅកាន់ទីដ៏សមគួរ ធ្វើដូច្នេះឈ្មោះថាព្រមព្រៀងធ្វើកិច្ចដែលសង្ឃត្រូវធ្វើ ។

៣ – ភិក្ខុមិនបញ្ញត្តថែមសិក្ខាបទដែលទ្រង់មិនបានបញ្ញត្ត មានសេចក្តីថា: ពួកភិក្ខុកាន់យកកតិកវត្ត មិនត្រូវតាមធម៌, កាន់យកសិក្ខាបទមិនត្រូវតាមធម៌ ឈ្មោះថាបញ្ញត្តថែមសិក្ខាបទដែលទ្រង់មិនបានបញ្ញត្ត ភិក្ខុសំដែងលទ្ធិសាសនាឲ្យឃ្លៀងឃ្លាតចាកធម៌វិន័យ ឈ្មោះថាបន្ថយសិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយ ដូចពួកវជ្ជីបុត្តកភិក្ខុសំដែងវត្ថុ ១០

ប្រការ  ជាចំនាស់ធម៌វិន័យដំនាន់ក្រោយពីព្រះអង្គទ្រង់បរិនិព្វានហើយ រវាង ១០០ ឆ្នាំនោះ (សេចក្ដីពិស្ដារមាននៅក្នុងគម្ពីរចុល្លវគ្គ) ។ ភិក្ខុក្នុងប្រព្រឹត្តកន្លងអាបត្តិតូច-ធំ ឈ្មោះថាមិនប្រព្រឹត្តសមាទានសិក្ខាបទគួរតាមបញ្ញត្តិដូចអស្សជិ និងបុនព្វសុកភិក្ខុទាំងពីររូបដែលប្រព្រឹត្តអនាចារផ្សេងៗ មានដាំដើមឈើមានផ្កា មានផ្លែ ផ្កាប់ផ្គុនត្រកូលជាដើមដែលមានបញ្ញត្តិក្នុងសង្ឃាទិសេស ត្រង់សិក្ខាបទទី ១៣ កាលបើភិក្ខុមិនបានធ្វើកន្លងដូចដែលសំដែងហើយក្នុងមាតិកាទី ៣ ខាងលើនេះទេ ឈ្មោះថាមិនបានបញ្ញត្តថែមសិក្ខាបទដែលទ្រង់មិនបានបញ្ញត្ត ។ ភិក្ខុប្រព្រឹត្តសមាទានតាមតែសិក្ខាបទដែលទ្រង់បញ្ញត្តហើយ ឈ្មោះថាសមាទានគួរតាមបញ្ញត្តិដូចព្រះឧត្តសេនត្ថេរ ព្រះយសកាកណ្ឌកបុត្តនិងព្រះមហាកស្សបដ៏មានអាយុជាដើម ។

៤ – ភិក្ខុអង្គណាជាធំជាថេរៈ... មានសេចក្ដីថា: ភិក្ខុប្រកបដោយគុណធម៌ដ៏មាំមួន ដឹងរាត្រីមុនគេ ព្រះជន្មក៏ច្រើន បួសក៏បានយូរជាបិតារបស់សង្ឃ ជាប្រធានរបស់សង្ឃ លោកតែងនាំភិក្ខុបីឲ្យប្រព្រឹត្តក្នុងត្រៃសិក្ខា ប្រសិនបើភិក្ខុបីមិនធ្វើសក្ការៈ មិនទៅកាន់ទីឧបដ្ឋាកក្នុង១ថ្ងៃ ២-៣ ដង ដើម្បីស្ដាប់ឱវាទរបស់លោកនោះ ព្រះថេរទាំងនោះនឹងមិនបានឲ្យឱវាទ មិនបានសំដែងពាក្យបវេណីប្រាប់ មិនបានឲ្យសិក្សាធម្មបរិយាយដែលមានខ្លឹមសារ ភិក្ខុបីនឹងសាបសូន្យចាកគុណមានសីលគុណជាដើម

និងអរិយទ្រព្យទាំង ៧ ប្រការដែលខ្លួនត្រូវបានបែរជាខានបានវិញ; បើភិក្ខុ ធ្វើសក្ការៈគោរពកប់អានតែងទៅកាន់ទីបំរើលោករឿយៗ ហើយលោកនឹងឲ្យឱវាទថា: អ្នកត្រូវឈានចូលដូច្នេះ ត្រូវឈានថយដូច្នេះ ទាំងសំដែងពាក្យបវេណីប្រាប់ ព្រមទាំងនាំឲ្យសិក្សាធម្មបរិយាយដែលមានខ្លឹមសារ លោកនឹងប្រៀនប្រដៅធុតង្គទាំង ១៣ កថាវត្ថុទាំង ១០ លុះភិក្ខុ តាំងនៅក្នុងឱវាទរបស់លោកហើយក៏នឹងបានដល់នូវសេចក្ដីចំរើនដោយសីលគុណហេតុដល់បានសម្រេចគុណវិសេសគួរដល់ប្រយោជន៍រៀងៗ ខ្លួនពុំឃ្លាតឡើយ ។

៥ – ភិក្ខុមិនលុះអំណាចតណ្ហា មានសេចក្ដីថា ភិក្ខុមិនត្រូវត្រាច់ទៅតាមត្រកូលឧបដ្ឋាករបស់ខ្លួនពីស្រុកមួយទៅស្រុកមួយ ដើម្បីស្វែងរកបច្ច័យ ៤ ដែលជាទំនាស់នឹងវិន័យពុទ្ធបញ្ញត្តិដូចោះឡើយ ត្រូវជាអ្នកប្រព្រឹត្តសន្ដោសក្នុងបច្ច័យទាំង ៤ គួរតាមមានតាមបាន ។

៦ – ភិក្ខុត្រូវមានសេចក្ដីអាល័យក្នុងសេនាសនៈស្ងាត់ មានសេចក្ដីថា ភិក្ខុអ្នកចំរើនឈាន កាលបើចូលឈានក្នុងសេនាសនៈជិតភូមិ ជិតស្រុកដែលមានមនុស្សនៅច្រើនកុះករ លុះចេញចាកឈានវិញក៏នឹងឮសំឡេងបុរសស្ត្រីទារកជាដើមហើយមានអារម្មណ៍ស្ទុះទៅផ្ដេសផ្ដាស ការត្រាស់ដឹងគុណវិសេសក៏នឹងសាបសូន្យទៅតាមអារម្មណ៍នោះៗ

(មានត)

**អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលបរិកជាតិ**

**អក្សរសាស្ត្ររលត់ ជាតិរលត់ ។**

## ប្រវត្តិឧកញ៉ាសន្ធរវោហារ - ម៉ុក

(១៨៤៦-១៩០៨)

ឧកញ៉ាសន្ធរវោហារ ម៉ុក កើតនៅក្រុងឧដុង្គក្នុង គ.ស. ១៨៤៦ ។ បិតាលោកធ្វើជានាម៉ឺនក្នុងព្រះបរមរាជវាំង (ឧដុង្គ) ត្រូវយួនកៀរទាំងគ្រួសារយកទៅស្រុកគេអស់កម្ពង់ជាយូរឆ្នាំ, ដូច្នេះអ្នកនិពន្ធនេះកាលនៅពីកុមារ មានសេចក្ដីកំសត់ក្រៃលែង ។

លោកគ្រូព្រះមហារាជធម្មព្រះនាម អន វត្តគុក ខាងកើតក្នុងព្រះរាជ-ទ្រព្យ មានព្រះទ័យអាសូរករុណា បានរើសកុមារកំព្រានេះកាលអាយុបាន ១១ ឆ្នាំ យកទៅឲ្យនៅវត្ត បង្ហាត់បង្រៀនអក្សរខ្មែរ ។ ពិតមែនតែការសិក្សាក្នុងជំនាន់នោះលំបាកខ្លាំង ព្រោះខ្វះគ្រឿងឧបករណ៍សម្រាប់រៀន ប៉ុន្តែកុមារម៉ុក ស៊ូណាស់ក្នុងការស្វែងឈោងចាប់យកចំណេះវិជ្ជា ។ ពេលយប់គ្មានប្រេងគ្មានចង្កៀងអុជរៀនទេ, កុមារធ្មេចតរៀនតែនឹងពន្លឺភ្លើងជើងក្រាន ដែលដាំតែប្រគេនលោក ហើយប្រើតម្បាញនឹងឥដ្ឋជំនួសដីសនឹងក្ដារខៀន ។ ព្រះមហារាជធម្មមានព្រះទ័យអាណិតអាសូរប្រោសប្រាណកុមារនេះជាងកុមារឯទៀត ។ រូបអាក្រក់ មុខមានស្នាមអុត ដៃ

ក្មែងទាំងសងខាង ព្រោះកើតជាមួយនេះកាលនៅពីតូច, កុមារម៉ុកបានទៅជាប្រដាប់សម្រាប់ក្មេងវត្តដូចគ្នា ចំអកឡកឡឺយសើចលេងជាល្បែង គេតែងពោលថា "ម៉ុកក្មែង-ម៉ែងកុក" ។

សម្ដេចព្រះវររាជជននីនាថនៃព្រះករុណានរោត្ដម តែងមានព្រះបន្ទូលឲ្យគេហៅ កុមារ ម៉ុក មកឯព្រះរាជដំណាក់ក្រុងឧដុង្គ ជាញឹកញយ ដើម្បីឲ្យមើលសាស្ត្រាថ្វាយទ្រង់ព្រះសណ្ដាប់ ព្រោះកុមាររូបអាក្រក់នេះមានសំឡេងក្រាងក្រអៅពិរោះអស្ចារ្យណាស់ ។ កាលនាយម៉ុកសឹកពីភិក្ខុមកវិញ, ព្រះមហារាជធម្មបាននាំខ្លួនទៅថ្វាយព្រះករុណាព្រះបាទសម្ដេចព្រះនរោត្ដមនៅក្រុងភ្នំពេញ ដើម្បីសូមជ្រកកោនក្រោមម្លប់ព្រះបរមរាជបារមីតទៅ ។ ការធ្លាប់បានគាប់ព្រះរាជហឫទ័យនៃព្រះវររាជ-ជននីនាថ ចំពោះនាយម៉ុកតាំងពីនៅជាកុមារ នាំឲ្យព្រះចៅក្រុងកម្ពុជាទ្រង់ព្រះមេត្តាប្រោសឲ្យធ្វើការក្នុងក្រុមព្រះអាលក្ខណ៍ (ប៉ែកខាងរោងពុម្ព) ។ នាយម៉ុកខំយកចិត្តទុកដាក់សង្វាតធ្វើការរាជការ ឲ្យបានចំរើនក្នុងមុខងាររបស់ខ្លួន ហើយធ្វៀតរៀនសូត្រតែងកាព្យឃ្លោងនិងច្បាប់ដំបូន្មានផ្សេងៗ មានវោហារសំដីថ្វីមាត់ពិរោះក្បោះក្បាយ អ្នកផងទាំងឡាយចូលចិត្តចោមស្ដាប់ណាស់ ។ ដោយមានសេចក្ដីអង់អាចគ្រប់គ្រាន់ក្នុងការរាជការ និងមានកិត្តិស័ព្ទល្បីល្បាញខាងកាព្យឃ្លោង ច្បាប់ទម្លាប់ផ្សេងៗ, ព្រះបាទសម្ដេចព្រះនរោត្ដមទ្រង់ប្រោសព្រះរាជទានយសសក្តិ និងគោរម្យ

ការជាឧកញ៉ាសុន្ទរវោហារចាន់ហ្វាន់ពេជ្រពុត្ម, លំដាប់តពីនោះមកទៀត ទើបលោកបានឡើងជាមេឃុំផ្ចាប់ ។ ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តមទ្រង់សព្វព្រះរាជហឫទ័យ ទឹងឧកញ៉ាសុន្ទរវោហារម៉ុកណាស់ ព្រោះលោកតែងឡើងគាល់ហៅជាញឹកញយ ហើយចេះតែងកាព្យឃ្លោង គ្រប់យ៉ាងថ្វាយព្រះរាជាបានតាមព្រះរាជបំណង ។ លោកមានវោហារ ជាពាក្យកាព្យ បានន័យដូចពាក្យរាយធម្មតា ។ មានដំណាលថា នៅវេលាដែលព្រះមហាក្សត្រ មានព្រះចិន្តានឹងទ្រង់ព្រះសណ្ដាប់ស័ព្ទ កាព្យសរសើរ ឬបង្អាប់ឬក៏ត្អូកកំប្លែងពីរឿងអ្វីមួយភ្លាមៗ, អ្នកនិពន្ធនេះ ក៏អាចសូត្របន្ទបានភ្លាមតាមព្រះរាជហឫទ័យឥតខ្ចោះ ។

គេហដ្ឋានរបស់លោកក្នុងជាន់នោះគឺនៅចំកន្ទេងគ្រឹស្ថាន 'ពង្សាអេ-វេឃុំវ៉េ" សព្វថ្ងៃនេះ ។ លោកបានជំនុំប្រឹក្សាអំពីវិជ្ជាផ្សេងៗជារឿយៗ ជាមួយនឹងពួកអ្នកប្រាជ្ញរាជបណ្ឌិតជាច្រើនក្នុងរដ្ឋរាជធានី ហើយបានតែង សាស្ត្រប្រលោមលោកជាច្រើន, តែយើងពុំអាចនឹករកគ្រប់ឈ្មោះឲ្យ ច្បាស់ក្នុងទីនេះបានទេ គ្រាន់តែប្រហាក់ប្រហែលគឺ សាស្ត្រវិមានច័ន្ទ, ទិព្វសង្វារ (?) ។ល។

ភរិយាលោកនាមជំទាវសម ។ លោកមានបុត្រាបុត្រីជាច្រើន, តែយើងស្គាល់ច្បាស់តែពីររូបគឺ លោកម៉ុក-សំអែលនិងម៉ុក-សំឌុក ។ លោកទីមួយបានធ្វើជាចៅហ្វាយខេត្ត ទទួលមរណភាពជាយូរឆ្នាំហើយ ។

ឯលោកទីពីរធ្វើជាគ្រូបង្រៀន មានស្នាដៃខាងអក្សរសាស្ត្រជាច្រើន ដូចមានរៀបរាប់ក្នុងប្រវត្តិរបស់លោកដែលចុះផ្សាយក្នុងទស្សនាវដ្ដី មិត្តសាលាបាលីលេខ ៦ ឆ្នាំ ១៩៥០ ។

លោកឧកញ៉ាសន្ធរពៅហារម៉ុក ទទួលមរណភាពនៅក្រុងភ្នំពេញ ក្នុង គ.ស. ១៩០៨ ។

ប្រវត្តិអ្នកនិពន្ធនេះ បើមានលោកអ្នកឯណាចាំជាក់ប្លែកជាងនេះ សូមមេត្តាសរសេរបញ្ជូនផ្ញើឲ្យសមាគមមិត្តសាលាបាលីឲ្យបាន ។ យើងសូមអរគុណច្រើនជាមុន ។

រឹម - គិន

---

ស្រឡាញ់ស្រីខ្មៅ ស្រីខ្មៅមានផៅ មានភ័ព្វត្រកាល ត្រកូលមានយស ខ្ពង់ខ្ពស់វិសាល វិសេសពៅពាល ពៅពេញដំទង់ ។

ដំទើរមានពង់ មានរូបស្អាតស្អាង ស្អាតស្អំសមទ្រង់ សមទ្រូងទូលាយ ឆោមឆាយត្រចង់ ត្រចះផូរផង់ ផូរភ័ក្ត្រថ្លាថ្លៃ ។

( ឧកញ៉ាសន្ធរពៅហារម៉ុក )

# គួរកសាងអនុស្សាវរីយ៍

## ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ថោងឬទេ?

នៅប្រទេសបារាំង គេបានកសាងប្រាសាទ ប៉ង់តេអុង «Panthéon» នៅប្រទេសអង់គ្លេស គេបានកសាងប្រាសាទវិសស្មិនស្ទ័រ (Westminster), នៅប្រទេសឯទៀត ក៏គេបានសាងប្រាសាទទំនងនេះដែរ សំរាប់បញ្ចុះសពព្រះរាជអ្នកប្រាជ្ញ ទឹងវីរបុរសរបស់គេទុកជាទីគោរពសក្ការបូជានឹងជាទីរឭកដល់វិញ្ញាណក្ខន្ធមហាបុរសនោះៗ ដែលបានធ្វើប្រយោជន៍ទុកឲ្យប្រទេសជាតិគេ ។ មហាបុរសទាំងឡាយនោះៗ បាននាមបញ្ញត្តិថាជាអមតបុគ្គល បុគ្គលមិនស្លាប់ (les immortels) ។ មិនតែប៉ុណ្ណោះទេ គេបានកសាងអនុស្សាវរីយ៍មហាបុរសនោះៗ ទុកតាមទីឋានផ្សេងៗ ទៀត ហើយចារឹកនាមនឹងប្រយោជន៍សំខាន់ៗ ដែលអ្នកប្រាជ្ញនឹងមហាបុរសនោះបានធ្វើទុកឲ្យប្រទេសជាតិ ។ ជនជាតិអស្ដគ្គតប្រទេស ពេញចិត្តណាស់ចង់ឲ្យគេយកសពខ្លួនទៅបញ្ចុះនៅក្នុងប្រាសាទសំរាប់បញ្ចុះសពអមត-បុគ្គលទាំងឡាយនោះ ព្រមទាំងចង់ឲ្យគេកសាងអនុស្សាវរីយ៍របស់ខ្លួនទុកផង បានជាជនជាតិគេម្នាក់ៗ ខំប្រឹងគិតរកឧបាយធ្វើប្រយោជន៍ដូចម្ដេចឲ្យមានកេរ្តិ៍ឈ្មោះល្បីល្បាញ ដើម្បីឲ្យបានឈ្មោះខ្លួនចូលរួមជាមួយសពអមតបុគ្គលទាំងឡាយ ។ មានមហាបុរសមួយពួកទៀត ជាអ្នកប្រាជ្ញធ្វើប្រយោជន៍ឲ្យពិភពលោកទាំងមូលដូចលោកប៉ាស្ទ័រ (Pasteur)

អ្នកប្រាជ្ញបារាំង ដូចមហាត្មគន្ធិ អ្នកប្រាជ្ញឥណ្ឌាជាដើម មហាបុរសពួកនេះ គេចាត់ជាបុរសវិសេសផុត សូម្បីប្រទេសណាៗ ក៏គេមិនប្រកាន់ គេកសាងអនុស្សាវរីយ៍អ្នកប្រាជ្ញពួកនេះ ទុកក្នុងប្រទេសគេរៀងរាល់ខ្លួន ៗ ចុះប្រទេសយើង? ខ្ញុំយល់ឃើញថាប្រទេសយើង មិនខ្សត់ខ្សោយអ្នកប្រាជ្ញពេកទេ មានច្រើនគួរសមដែរ មហាបុរសយើងដែលបាត់បង់ទៅហើយក៏មាន នៅក្នុងបច្ចុប្បន្នកាលនេះក៏មានដែរ ថាបើមិនមាន ប្រទេសយើងគង់មិនអាចតាំងនៅបានរហូតដល់កាលសព្វថ្ងៃនេះទេ ៗ តែគួរអនិច្ចាមហាបុរសយើង ដែលបាត់បង់ទៅក្នុង ៤ សតវត្សរ៍កន្លងទៅហើយនេះ បាត់នាមបាត់រូបសូន្យឈឹង ដូចមនុស្សអនាថាមិនបានទទួលកិត្តិយសថាជាអមតបុគ្គលដូចគេ ព្រមទាំងមិនមាននរណានឹកឃើញថាគួរនឹងកសាងជាអនុស្សាវរីយ៍ទុកជាទីគោរពសក្ការបូជា នឹងជាទិដ្ឋានុគតិដល់បច្ឆាជនរបស់យើងទៅអនាគត ៗ ហេតុដូច្នេះហើយបានជាយើងខ្វះអ្នកប្រាជ្ញមានកេរ្តិ៍ជាអ្នកនាំមុខ? ដោយខ្ញុំនឹកឃើញដូច្នេះជាដើមហេតុ ទើបខ្ញុំសរសេរស្នើមតិអស់លោកទាំងឡាយ ៗ ខ្ញុំសូមលើកយកអ្នកប្រាជ្ញមួយអង្គ តាមដែលខ្ញុំយល់ឃើញថាសមគួរនឹងនិយាយក្នុងពេលនេះ គឺព្រះតេជព្រះគុណព្រះមហាវិមលធម្ម នាម ថោង ៗ

ព្រះមហាថេរៈអង្គនេះជាអ្នកប្រាជ្ញមួយអង្គ ដែលគេរកបានដោយក្រ បណ្តាអ្នករកបានដោយក្រទាំងឡាយ ៗ លោកមានគុណសម្បត្តិ

ពិសេសប្លែក គ្រូមានគុណសម្បត្តិអ្នកប្រាជ្ញក្នុងប្រទេសយើងប្រដូចបានៗ ត្រកូលលោកជាត្រកូលអភិជន តែលោកមិនប្រកាន់ខ្លួនប្រាណទីងកិត្តិ·យសទេ ៗ ឫកពាកិរិយាសុភាពមិនទាបមិនខ្ពស់នៃលោក ជាទីពេញចិត្តជនានុជនទាំងពួង ៗ

រាងពៅកណ្ដាលមិនទាបមិនខ្ពស់ និមន្តស្អៀងផ្អៀងខាងស្តាំបន្តិច ហើយដំណើររហ័សរហ័ន ពណ៌សម្បុរស្បែកសណ្ដែកបាយ ព្រះនេត្រស្រលៀងខាងស្ដាំ ធំប៉ុនតូចគល់ ថ្ងាសវែង ត្រចៀកធ្លាក់យារ ព្រះភក្ត្រស្រស់ស្រាយ ពុទ្ធដីកាស្រទន់ពីរោះ ចរិយាសុភាពរាបសា ព្រះទ័យស្មោះត្រង់, ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ថោង មានគុណ-សម្បត្តិប្រកបដោយដម្លៃដ៏ខ្ពង់ខ្ពស់ជាលក្ខណបុរសដ៏ប្រសើរ លោកជាអ្នកប្រាជ្ញ មានប្រាជ្ញាមុះមុត ហើយយកការចេះដឹងទៅប្រើជាប្រយោជន៍ មានគំនិតព្រោងមើលឃើញឆ្ងាយ មានយោបល់ជ្រៅឆ្ងាយហើយឥតល្អៀង ៗ ការងារលោកម៉ឺងម៉ាត់ ហើយយ៉ាងជាប់ខាត បើកាន់ការអ្វីការនោះញ៉ាំរហើយសំរេច ៗ ព្រះទ័យលោកជូនទៅកាន់ការសិក្សាសព្វវិជ្ជា ដោយច្រើនបំពោះព្រះពុទ្ធសាសនា ៗ ដែលអ្នកផងតែងសរសើរ គឺលោកមានព្រះទ័យស្រឡាញ់រាប់អានអ្នកចេះដឹងទូទៅ មិនថាភិក្ខុសាមណេរ ឬ គ្រហស្ថ មិនថាធម្មយុត្តិ ឬ មហានិកាយ ឬពុំនោះអ្នកមានទ្រព្យមានបុណ្យស័ក្តិឡើយ ៗ

សាលាភាគរដ្ឋប្រជាជាតិកម្ពុជា
បណ្ណាល័យលេខ ២៥
លេខទុក :

ក្នុងជំនាន់ខ្ញុំ, ខ្ញុំបានដឹងបានស្គាល់អស់លោកច្រើនរូប ដែលមានកិត្តិយសបានទទួលការរាប់អាន ទីពឹងទំនុកបំរុងរបស់ព្រះមហាថេរអង្គនេះ ៗ តាមខ្ញុំពិនិត្យឃើញថា សន្តានចិត្តលោកដែលសំដែងការរាប់អានអ្នកបេះដូងនេះហួសព្រំដែន ព្រោះលោករាប់អានមិនកំណត់បក្សពួក មិនរើសនិកាយ គឺចំពោះតែអ្នកបេះដូងមួយមុខ ព្រមទាំងមិនថាអ្នកបេះដូងវិជ្ជាអ្វី ៗ មានអស់លោកខាងគណៈធម្មយុត្តិខ្លះ បានទទួលការរាប់អានពីអង្គលោករាប់អានជាវិស័យមាតាបិតាចំពោះបុត្រធីតា មិនមែនរាប់អានតែមាត់ដូចអ្នកផងទាំងពួងទេ ព្រោះកាលខ្លះ ក្រៅពីកាលសម័យដែលលោកត្រូវសម្រាកដោយចតុប្បច្ច័យ ឬលោកឲ្យហៅគេមកប្រស្រ័យជាធម្មតា បើលោកបានដឹងថាអ្នកអស់នោះមានជម្ងឺ, លោកក៏និមន្តទៅសាកសួរថែរក្សាថ្នាក់ថ្នមដូចមាតាបិតាថ្នមកូន ៗ ការរាប់អានហួសព្រំដែនបែបនេះ ខ្ញុំបានដឹងជាក់ពីសំណាក់អស់លោកគណៈធម្មយុត្តិ មកសរសើរពីគុណសម្បត្តិអង្គលោកប្រាប់ខ្ញុំ ៗ សព្វថ្ងៃនេះ នៅមានអស់លោកគណៈធម្មយុត្តិខ្លះ ដែលបានទទួលការរាប់អាន ហើយចាំជាក់នូវកិច្ចការទាំងអស់ពីសំណាក់លោក ៗ

ដើមឡើយ ខ្ញុំមិនគួរនឹងមានកិត្តិយសបានស្គាល់លោកទេ ព្រោះកាលនោះខ្ញុំជាកូនសាមណេរតូច អាស្រ័យរៀនសូត្រនៅក្នុងព្រះតេជ-ព្រះគុណព្រះមហាវិមលធម្ម គង់ កាលនៅជាព្រះធម្មកវីវង្ស ដែលជាមិត្រ

ភ័ក្តិនឹងអង្គលោកដែរ ។ កាលខ្ញុំប្រឡងចូលរៀនសាលាបាលីជាន់ខ្ពស់ផុតហើយ ខ្ញុំត្រូវប្រឡងចូលរៀនភាសាបារាំងផ្នែកខាងធ្វើគ្រូទៀត កាលនោះ ខ្ញុំមានសំណាងបានពិន្ទុប្រសើរជាងគេ ។ តាំងពីកាលនោះមក ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ថោង ចាប់ផ្តើមរាប់រកខ្ញុំ ចាត់គេទៅហៅខ្ញុំឲ្យមកកាន់សំណាក់លោក ។ នេះជាបឋមហេតុ ដែលនាំឲ្យខ្ញុំមានកិត្តិយសបានស្គាល់អង្គលោក ព្រមទាំងបានទទួលការរាប់អានដ៏ខ្ពស់ពីអង្គលោកផង ។ ខ្ញុំចូលទៅ, លោកមានពុទ្ធដីកាបចាកអរាក ព្រះភ័ក្ត្រស្រស់ស្រាយ សំដែងសេចក្តីស្និទ្ធស្នាល ធ្វើឲ្យខ្ញុំអាចហ៊ាន, តែពេលនោះ ខ្ញុំមិនហ៊ានចូលទៅជិត ព្រោះខ្ញុំមិនដែលបានទទួលកិត្តិយសបែបនេះសោះ លុះដាក់ខ្លួនចុះហើយក្រាបថ្វាយបង្គំ ដោយសេចក្តីគោរពពីចម្ងាយ ទើបលោកបង្ខំឲ្យចូលទៅជិតអង្គលោកទៀត ខ្ញុំខិតចូលទៅជិតអង្គុយបត់ជើងប្រុងចាំស្តាប់ពុទ្ធដីកាលោក ។ តទៅលោកមានពុទ្ធដីកាប្រស្រ័យជាមួយខ្ញុំ ហាក់ដូចជីតានិយាយរឿងព្រេងប្រាប់កូនចៅដូច្នោះ ។ មុនដំបូង លោកមានពុទ្ធដីកាថា ក្រុងភ្នំពេញនេះ កាលដែលផ្លាស់ក្រុងពីឧត្តុង្គមានជ័យមក ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម មកធ្វើវាំងតាក់នៅត្រង់ផ្សារកណ្តាល រង់ចាំទម្រាំចាត់ចែងកសាងព្រះបរមរាជវាំងចតុមុខហើយស្រេច ។ លោកមានពុទ្ធដីកាសំណេះសំណាលជាមួយខ្ញុំអស់កាលយូរ តែពីពង្សាវតារប្រទេសយើង ហាក់ដូចជាពន្យល់ខ្ញុំឲ្យ

ស្គាល់ពន្ធនាគារ ព្រោះលោកបេះដាំច្រើនហើយសព្វព្រះទ័យមានពុទ្ធដីកាផង ៗ ទីបំផុតលោកឲ្យឱវាទខ្ញុំឲ្យខំប្រឹងរៀនសូត្រតទៅកុំខ្ជិលច្រអូស ៗ ខ្ញុំត្រឡប់មកកុដិវិញសប្បាយចិត្តណាស់ សរសើរភ័ព្វសំ-ណាងថាបានមកសមាគមមួយអន្លើដោយអ្នកប្រាជ្ញធំ សន្ទានជាសប្បុរស ខ្ញុំត្រាទុកនូវការជួបនេះជាកិត្តិយសដ៏ខ្ពង់ខ្ពស់ក្នុងជីវិតរបស់ខ្ញុំដែលមិនមានអំពូអន្ធការអ្វីអាចចូលមកធ្វើឲ្យសៅហ្មងបាន រហូតដល់ទីបំផុតជីវិតខ្ញុំ ៗ ខ្ញុំស្មានថាខ្លួនខ្ញុំនេះជាអ្នកដែលបានទទួលការរាប់អានក្រោយគេបង្អស់ ព្រោះតាំងពីកាលនោះមកមិនយូរប៉ុន្មានលោកក៏មានអាពាធធ្ងន់ ហើយនិមន្តទៅកាន់បរលោកទៅ ៗ ខ្ញុំយល់ថាលក្ខណសម្បត្តិអង្គលោកមានដម្លៃថែបនេះកម្រមានណាស់ ខ្ញុំស្ទើរតែហ៊ាននិយាយឥតសំចៃមាត់ថាឥតមានលោករូបណាមួយប្រាកដដូចអង្គលោកឡើយ ថាបើមាន សូម្បីតែពីរបីរូប សភាពពុទ្ធសាសនាឬសភាពប្រទេសជាតិ មុខជាមិនអារ៉ះអ្នកប្រាជ្ញដូចកាលបច្ចុប្បន្ននេះទេ ៗ ឱហ្ន៎! ធ្វើម្តេចឡើយ យើងនឹងមានភ័ព្វសំណាងបានទទួលសម្ភពកំណើតអ្នកប្រាជ្ញ មានគុណសម្បត្តិមានដម្លៃប្រាកដដូច្នេះនៅក្នុងប្រទេសយើងទៀត? ៗ ហេតុដែលក្រីក្រខ្សត់បុរសអាជានេយ្យយ៉ាងនេះហើយ បានជាព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកថា:

“បុរសអាជានេយ្យ ជាបុគ្គលរកបានដោយក្រ មិនដែល
កើតមានសព្វទីកន្លែងទេ បើបានកើតឡើងក្នុងត្រកូលណា
ត្រកូលនោះនឹងបានសេចក្ដីសុខ” ។

ការស្រ័យដោយអគ្គលោក ជាអ្នកនាំផ្លូវមុនមានយោបល់ក្លីថា តាំងពីអ្នកផងកំពុងដេកលក់, ក្នុងការដឹកនាំប្រទេសជាតិនិងពុទ្ធសាសនាទៅកាន់សេចក្ដីចំរើននោះ ទើបព្រះមហាថេរអង្គនេះត្រូវរកអ្នកចេះដឹង ប្រមូលកៀរគរអ្នកចេះដឹងឲ្យបានច្រើនគ្នា យកអ្នកចេះដឹងជាត្រីមុខ ដើម្បីជួយស្រោចស្រង់ ឧបតប្រទេសជាតិនិងពុទ្ធសាសនា ដែលជាការៈធ្ងន់បំផុតឲ្យចំរើនបាន ។ រឿងនេះនាំឲ្យខ្ញុំនឹកដល់កាលដែលខ្ញុំអានពង្សាវតារបារាំង ឃើញជីវិតប្រទេសបារាំងក្នុងរាជវង្ស ព្រះបាទល្វីស៍ទី ១៣ (Louis XIII) ក្នុងរាជ្យនេះ មានមហាបុរសម្នាក់ឈ្មោះរីស៊ីលីយើរ (Richelieux) ជាទីប្រាសប្រាណរបស់ព្រះអង្គ ។ អ្នកប្រាជ្ញនេះ ជាអ្នកឲ្យកំណើតប្រទេសបារាំង បានបង្កើតកងទ័ពនាវាអាចប្រដែងមុខអង់គ្លេស ដែលជាម្ចាស់សមុទ្រកាលគ្រានោះ បានប្រមូលច្បាប់ដែលហៅមីស៊ូ (Michau) បានប្រទេសចំណុះ ៥ កន្លែង រួមទាំងកាណាដាផង បានតាំងមហាវិទ្យាល័យ សរបោន (sorbonne) ដែលជាស្ថានទីសិក្សាសំខាន់ទីបំផុត នៅបារីសក្នុងវេលានេះ បានតាំងបណ្ណាល័យនឹងរោងពុម្ពជាតិ ព្រមទាំងបានតាំងអាកាដេមីបារាំងសែស ជាសភាសំខាន់ទី

បំផុត ជាសកាអ្នកប្រាជ្ញសុទ្ធសឹងជាអមតបុគ្គលសំរាប់ជំនួយការបេះដូងដល់ប្រទេស ។ លោកល្វីស៍-ម៉ាដឺឡាំង (L. Madelin) អ្នកប្រាជ្ញប្រវត្តិសាស្ត្របារាំងបានសរសេរសរសើរលោករីស៊ីលីយ៉េរថា "គ្រាន់តែកើតឡើងក្នុងលោកហើយ ក៏បេះស្រឡាញ់ស្រុកទេសនឹងព្រះមហា-ក្សត្រិយ៍តែម្ដង" ។

បើយើងក្រឡេកមើលទៅលើទំព័រដើរប្រវត្តិព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង យើងនឹងឃើញសេចក្ដីថា:

"ទ្រង់ប្រមូលព្រះអរហន្តបានច្រើនអង្គ សុទ្ធតែជាអ្នកបេះដូង ហេតុដល់សញ្ជ័យពោលបញ្ឆិតបញ្ឆៀងឲ្យឧបតិស្សនិងកោលិតថា "អ្នកណាប្រាជ្ញទៅចុះ អ្នកណាល្ងង់នៅជាមួយខ្ញុំ" បានជាក្នុងពុទ្ធកាល ព្រះពុទ្ធ-អង្គទ្រង់ចោមរោមដោយព្រះអរហន្តាខីណាស្រព, ពួកនិគ្រន្ថ មានសុទ្ធតែពួកអបេល" ។ ក្នុងការវែករកផ្លូវតម្រឹកព្រះពុទ្ធសាសនា ក្នុងប្រ-ទេសយើង ព្រះរតនព្រះគុណព្រះមហាវិមលធម្ម ថោង មានយោបល់វិសេសមួយគឺ "ប្រមូលអ្នកបេះដូងដែលហៅថា វិញ្ញូជន ឲ្យបានច្រើននាក់" ។ ទើបកាលនោះ អង្គលោកចោមជុំវិញដោយបរិវារសុទ្ធសឹងអ្នកប្រាជ្ញ ក្រៅពីនេះនៅសល់តែមនុស្សអសង់ដើស ។

កាលដែលអង្គលោកអនិច្ចធម្មទៅហើយ អស់លោកអ្នកប្រាជ្ញទាំងឡាយសរសេរពីគុណសម្បត្តិលោកជាអនេកន័យ, ខ្ញុំសូមស្រង់

សេចក្ដីខ្លះៗ មកពោលបញ្ជាក់ដូចតទៅនេះ ។ ព្រះតេជព្រះគុណព្រះពោធិវ័ង្ស ហ-គាត កាលនៅជាព្រះគ្រូសំវិជ្ជា បានសរសេរទុកថាៈ—

"គុណរបស់លោក (ព្រះតេជព្រះគុណព្រះមហាវិមលធម្មថោង) ដែលមានចំពោះមកលើខ្លួនខ្ញុំនោះ មិនត្រឹមតែដោយហេតុដែលបានពណ៌នា ដូចខាងលើនេះឡើយ មានក្រៅពីនេះច្រើនទៅទៀត ដូចកាលដែលខ្លួនខ្ញុំទើបនឹងបានឧបសម្បទាថ្មីៗ គិតមកដល់ឥឡូវនេះចំនួន ១៦ ឆ្នាំហើយ កាលនោះ លោកពុំទាន់ស្គាល់ខ្ញុំដោយជាក់លាក់នៅឡើយលុះដល់សម័យដែលខ្ញុំបានចូលប្រឡងប្រយោគបែបបាលី នៅទីឧបោសថវត្តនាគមវិហារព្រះកែវមរកតបាន ៤ ប្រយោគលោកក៏បានស្គាល់ខ្ញុំជាក់លាក់ហើយមានព្រះទ័យរាប់អានខ្ញុំ តាំងពីនោះរៀងមកលោកទំនុកបំរុងសង្គ្រោះឲ្យខ្ញុំមានកម្លាំងក្នុងការរៀនសូត្រចំពោះវិជ្ជាខាងផ្លូវពុទ្ធសាសនា ... ។ តាមដែលខ្ញុំសង្កេតមើលទៅឃើញថា ដែលលោករាប់អាននឹងសង្គ្រោះទំនុកបំរុងឲ្យរៀនសូត្រនោះ មិនតែខ្លួនខ្ញុំមួយនេះទេ មានច្រើនណាស់ដែលលោកទំនុកបំរុងយ៉ាងនេះ ហើយលោកនឹងត្រូវការចង់បានអ្វីពីអ្នកណាដែលលោកទំនុកបំរុងនោះមិនឃើញមានឡើយ" ។

សម្ដេចព្រះមហាសុមេធាធិបតី ជ-ណាត កាលនៅជាព្រះគ្រូសង្ឃសត្ថា សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ សរសេរដំណាលតាមពុទ្ធ-

ដីកាព្រះតេជព្រះគុណព្រះមហាវិមលធម្មថោង តាមដែលសម្តេចធ្លាប់បានស្តាប់រឿយៗ ចំពោះពីព្រះឱស្ឋលោកថា :

"លោកសង្ឃស្ទា! ខ្ញុំមានសេចក្តីពេញចិត្តស្រឡាញ់អបរិហានីយធម៌ ៧ យ៉ាង ជាពុទ្ធភាសិតដែលមានក្នុងគម្ពីរអង្គុត្តរនិកាយនោះអីម្ល៉េះទេ ប្រសិនបើយើងអ្នកទាំងអស់គ្នាសព្វថ្ងៃនេះ យកចិត្តទុកដាក់ប្រព្រឹត្តឲ្យត្រូវតាមអបរិហានីយធម៌ទាំង ៧ យ៉ាងនោះ ព្រះពុទ្ធសាសនានឹងចម្រើនរុងរឿងណាស់ ប៉ុន្តែយើងសព្វថ្ងៃនេះ យើងទៅជាមិនអើពើ មិនយកចិត្តទុកដាក់នឹងអបរិហានីយធម៌ទាំង ៧ យ៉ាងនោះសោះ ព្រោះហេតុហ្នឹងបានជាយើងអ្នកបួសទាំងអស់គ្នាសព្វថ្ងៃ បេះតែរកាំរកូសនឹងគ្នា ខ្លះពេញចិត្តស្រឡាញ់ការរៀនសូត្រ ខ្លះមិនសូវពេញចិត្ត ក៏មិនសូវសង្កាត់រៀនសូត្រ ហើយមានខ្លះថែមទាំងស្អប់អ្នករៀនសូត្រនោះទៅទៀត បើស្អប់អ្នករៀនធម៌របស់ព្រះហើយ ក៏ឈ្មោះថាស្អប់ដល់ព្រះដែរ បើថាស្អប់ក៏ស្អប់តែមនុស្សទៅចុះអេះ នេះមានថែមទៅស្អប់ទាំងធម៌ផង ហើយមានថែមទាំងពោលពាក្យតិះដៀលដល់ធម៌របស់ព្រះទៅទៀត តិះដៀលធម៌ព្រះរួចខំប្រឹងសំពះព្រះថាយកបុណ្យ ខ្ញុំសព្វថ្ងៃដែលបានរៀនសូត្របេះដឹងប៉ុណ្ណឹង ការប្រព្រឹត្តិរបស់ខ្ញុំឬបយទេ ខុសខ្លះត្រូវខ្លះ ប៉ុន្តែឲ្យលោកសង្កេតមើលចិត្តខ្ញុំចុះ ខ្ញុំមិនដែលតាំងចិត្តស្អប់ឬព្យាបាទប្រទូស្តកស្យាឈ្នានីសដល់អ្នករៀនធម៌វិន័យ មិនដែលហ៊ានពោលពាក្យតិះដៀលធម៌

ព្រះដល់ម្តងទេ ខ្ញុំស្រឡាញ់ព្រះត្រៃបិដកណាស់ ព្រោះហេតុហ្នឹងបានជាខ្ញុំទិញសាងគម្ពីរព្រះត្រៃបិដក មិនដែលខាននៅឆ្នាំណាមួយទេ ដូចលោកឃើញខ្ញុំស្រាប់...." ។

មិនត្រឹមតែជាតិខ្មែរទេ ដែលសរសេរសរសើរគុណសម្បត្តិលោក សូម្បីព្រះអង្គម្ចាស់ ក្រុមព្រះតំរង់រាជានុភាពអ្នកប្រាជ្ញសៀម នឹងលោកល្វីស-ហ្វីណូត៍អ្នកប្រាជ្ញបារាំង ក៏បានស្ងើចសរសើរលោកជាអនេកបរិយាយ ។ លោកល្វីស-ហ្វីណូត៍សរសេរសរសើរលោកទុកថា :—

—"...... ក្នុងចំណោមមិត្តរបស់លោកទាំងប៉ុន្មាននោះខ្ញុំស្មានថា ខ្ញុំអាចនឹងរាប់ខ្លួនខ្ញុំមួយបញ្ចូលផងបាន ។ អស់លោកដែលធ្លាប់ស្និទ្ធស្នាលនឹងព្រះថេរៈនេះ នឹងពោលពាក្យដូចខ្ញុំ អំពីជីវប្រវត្តិរបស់លោក នឹងកិរិយារបស់លោក ដែលជាទីនាំឲ្យសាធារណជនស្រឡាញ់រាប់អានឲ្យទៅ......ដែលខ្ញុំមានប្រាថ្នានឹងរំលឹកយកមកដើម្បីជាទីៈគារពបំផុតរបស់ខ្ញុំនោះ គឺសេចក្តីឧស្សាហ៍របស់លោក ដែលលោកខំខ្នះខ្នែង ដើម្បីជ្រោមជ្រែងឲ្យបានពុទ្ធសាសនិកជនមានសិល្បសាស្ត្រខ្ពង់ខ្ពស់ឡើង ...... គឺក្នុងពេលនោះហើយ ដែលខ្លួនខ្ញុំនឹងលោកបានចងមេត្រីនឹងគ្នា, ចំណងមេត្រីនោះ មានតែមរណៈទេ ដែលមកផ្តាច់បាន ...... ខ្ញុំស្មានថា សម្តេចព្រះមហាសង្ឃរាជ កាលគង់ព្រះជន្មនៅឡើយ នោះទ្រង់មិនបានភ្នកក្នុងព្រះទ័យថា ទំនៀម

ទំលាប់បុរាណនោះ ទឹងតែសម្រួលខ្លះឲ្យបានស្រួលទៅតាមសម័យថ្មី
ទេ ឯចំណែកព្រះមហាវិមលធម្មនេះ លោកពិចារណាផ្សេងទៅទៀត
វិញ ខ្លួនលោកក៏ជាអ្នកកាន់ទំនៀមទំលាប់បុរាណដូច្នោះដែរ ហើយ
លោកក៏មិនដែលគិតថានឹងបោះបង់ទំនៀមទំលាប់ចោលឡើយ ប៉ុន្តែ
លោកយល់ឃើញថា ការរៀនសូត្រតែមួយមុខ ៗ នោះមិនគួរសោះ
ឡើយ ...... មិនត្រូវតាំងចិត្តប្រាថ្នាបែបយ៉ាងខ្លួនចាស់គ្រាំគ្រា
ដែលមិនហ៊ានឆ្លងកាត់ឈូងសមុទ្រពីត្រើយម្ខាងទៅត្រើយម្ខាង ដោយ
ឃើញធំទូលាយណាស់ ហើយក៏បណ្ដោយឲ្យលិចបន្តិចម្ដងៗ ដល់ទៅ
បាតសមុទ្រដែលគ្មានរលកនោះទៅ ។ .....ព្រោះតែសេចក្ដីចំប្រឹង
របស់លោកហើយ បានជាសព្វថ្ងៃសាលានេះ បានចំរើនឡើងគគាក់
ហើយមនុស្សប្រជុំចិត្តគ្រប់គ្នា ប្រហែលជាមានមនុស្សខ្លះ នឹកថាសាលា
បាលីនេះ មិនទាន់បានធ្វើការអ្វីឲ្យមានប្រយោជន៍ដល់មនុស្សដែលត្រូវ
ការនៅឡើយទេ? ប៉ុន្តែការដែលផ្ដើមថ្មី ហើយប្រសើរដូច្នេះ ត្រូវតែឲ្យ
មានពេលទើបធ្វើបាន តោងយើងមានសង្ឃឹមជឿទុកក្នុងចិត្តចុះថា "ផ្លូវ
ទៅអនាគតនេះ ព្រះថេរៈអង្គនេះបានកសាងហើយ" ។ ....
អំពើនេះនៅរស់ជានិច្ចក្នុងកិច្ចការទាំងឡាយ ដែលខ្លួនលោកជាមេគំនិត
សូមឲ្យលោកណាដែលទទួលកាន់កាប់ការជាខាងក្រោយប្រព្រឹត្តធ្វើតាម
គន្លងនេះ ហើយយកតម្រាប់តទៅ" ។

មុនបញ្ចប់ ខ្ញុំសូមដកស្រង់យកបច្ឆិមវាចាព្រះតេជព្រះគុណព្រះមហាវិមលធម្ម (ថោង) ជាវាចាមានតម្លៃបំផុតតាមសេចក្ដីដំណាលដែលព្រះតេជព្រះគុណព្រះឧត្ដមមុនី អ៊ុំ-ស៊ូ កាលនោះជាព្រះគ្រូវិមលបញ្ញា បានសរសេរទុក ដើម្បីបញ្ជាក់ថាអង្គលោកមានអាពាធធ្ងន់ណាស់ទៀបនឹងចូលទៅកាន់មាត់មច្ចុរាជហើយ ក៏នៅជាប់ព្រះទ័យចំពោះសេចក្ដីចំរើនពុទ្ធសាសនា មិនបាននឹកនាដល់រាងកាយលោកឡើយ ទំរើងទូន្មានសិស្សគណផ្ដែផ្ដាំទុកដូច្នេះថា:

" ..... ណ្ហើយចុះលោកគ្រប់អង្គ! ត្រង់ពេលពាក្យខ្ញុំនេះ ក៏ជាការទម្ងន់ដល់លោកហើយៗ លោកក៏បានធ្វើបដិការគុណដល់ខ្លួនខ្ញុំរួចជាស្រេចហើយ តែថាការឈឺស្លាប់នេះជារបស់ធម្មតាសម្រាប់សត្វទេ មិនដែលសត្វណាចៀសរួចឡើយ សូមអស់លោកយកព្រះទ័យទុកដាក់ជួយថែទាំទំនុកបំរុងសង្គ្រោះព្រះពុទ្ធសាសនាឲ្យបានចំរើនរុងរឿងឡើង ព្រោះការដែលឈឺចាប់ស្លាប់បាត់នេះ ជាការតូចបន្ទាប់បន្សំទេ គ្រាន់តែផ្លាស់រូបនេះចោល ទៅរករូបថ្មីទៀតប៉ុណ្ណោះទេ ឯការដែលធំធ្ងន់មាំមួនគ្រប់ខ្លួនសត្វរាល់គ្នានោះគឺព្រះពុទ្ធសាសនាឯណោះ....."

សេចក្ដីដូចបានរៀបរាប់មកនេះ ឃើញថាព្រះតេជព្រះគុណ-ព្រះមហាវិមលធម្ម ថោង ជាមេនាំឲ្យការសិក្សាពុទ្ធសាសនាបានចំរើនឡើង អង្គលោកជាអ្នកដឹកនាំមុន ជាចាងហ្វាងសាលាបាលីជាន់

ខ្ពស់ ជាមេគំនិតមួយក្នុងការនាំបង្កើតព្រះរាជបណ្ណាល័យនិងពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងកិច្ចការឯទៀត ដែលជាប្រយោជន៍សំខាន់ៗផង ៗ

រូបអង្គលោកបាត់បង់ទៅពិតមែន តែកិច្ចការរបស់លោកមិនបាត់ទេ នៅរស់រវើកសព្វថ្ងៃនេះ សេចក្ដីរុងរឿងនៃព្រះពុទ្ធសាសនានៅប្រទេសយើងប្រាកដជាកើតចេញពីរស្មីដួងវិញ្ញាណក្ខន្ធរបស់លោក ខ្លួនយើងគ្រប់គ្នាដែលបានចេះដឹងព្រះពុទ្ធសាសនាមកប៉ុណ្ណឹង ក៏អាស្រ័យដោយរស្មីគំនិតលោកជាប្រធាន ដូចលោកល្វីស៍ - ហ្វីណូត៍សរសេរថា "គោង សង្ឃឹមជឿទុកចិត្តចុះថាផ្លូវទៅអនាគត ព្រះថេរៈអង្គនេះបានកសាងហើយ" ដោយលោកបានធ្វើប្រយោជន៍សំខាន់ ៗ ទុកឲ្យប្រទេសជាតិដូច្នេះ សមគួរណាស់លោកទឹងបានទទួលកិត្តិនាមថាជាអមតបុគ្គល ហើយមានអនុស្សាវរីយ៍ទុកស្ទង់អង្គលោកជាទីសក្ការៈគោរពបូជា ព្រមទាំងជាប្រយោជន៍ដ៏ឧត្ដមសម្រាប់បច្ឆជនរបស់យើងតរៀងឆ្ងាយទៅអនាគត ៗ

ភិក្ខុ ប៉ាង-ខាត់

## បញ្ញត្រៃ:

(តមកពីលេខ ១២ ឆ្នាំ ១៩៥០)

មិនមែនតែសេវកាមាត្យប៉ុណ្ណោះទេដែលត្រូវការចិញ្ចឹមជីវិត ដោយពិត គឺលោកទាំងមូលនេះឯង ដែលស្ថិតនៅក្នុងឧបាយប្រព័ន្ធផ្សេងៗ មានសំដីពីរោះជាដើម ព្រោះតែស្វែងរកអាហារចំអែតផ្ទៃតែមួយមុខប៉ុណ្ណោះ អស់កប្បអស់កាល ព្រោះថា:

១៥៥ – ព្រះរាជាស៊ីពីប្រជារាស្ត្រ ពេទ្យពីមនុស្សឈឺ ពាណិជពីអ្នកទិញ អ្នកប្រាជ្ញពីមនុស្សល្ងង់ ។

១៥៦ – ចោរពីមនុស្សប្រមាទ អ្នកសូមពីអ្នកនៅផ្ទះ ស្រីផ្កាមាសពីអ្នកឆ្កួតកាម, ឯអ្នកមានសិល្បវិជ្ជាពីមនុស្សទាំងអស់ ។

១៥៧ – ជនទាំងឡាយមានព្រះរាជាជាដើមនេះ ចាប់នរជនទាំងយប់ទាំងថ្ងៃ ដោយអន្ទាក់ទាំងឡាយដែលធ្វើពីសំដីពីរោះទន់ភ្លន់ជាដើម ហើយស៊ីតាមចិត្ត ដូចត្រីចាប់គ្នាឯងស៊ីដូច្នោះ ។

១៥៨ – ចំណង់សត្វពស់ មនុស្សប្រព័ន្ធ និងចោរលួចទ្រព្យ ជនដទៃទាំងឡាយ មិនសម្រេចទាំងអស់ទេ ព្រោះហេតុនោះហើយបានជាមនុស្សលោកនេះ ប្រព្រឹត្តទៅបាន ។

១៥៩ – ពស់ជាសង្ខារនៃព្រះសម្ភុ(១) ដែលមានសេចក្ដីឃ្លានបៀតបៀនហើយ ចង់ស៊ីកណ្ដុររបស់ព្រះគណបតី(២); ក្ងោកជាជំនិះនៃ

---

១ ព្រះឥសូរ ។ ២ ព្រះគណេសជាបុត្រាព្រះឥសូរ ។

ព្រះកៅតញ្ញរិបុ[១] ...... ចង់ស៊ីពស់ជាសង្វារនៃព្រះសម្ភុនោះ; សីហៈជាជំនិះនៃនាងគិរីសុតា[២] ចង់ស៊ីក្ងោកនៃព្រះកៅតញ្ញរិបុនោះ ជាបើ ការព្យាយាមលួចធ្វើដូច្នេះ មាននៅក្នុងគេហដ្ឋានព្រះសម្ភុទៅហើយ ម្ដេចឡើយមិនគប្បីមានក្នុងផ្ទះនៃជនដទៃទៀត? នេះហើយជាសភាពប្រក្រតី ដែលមាននៅក្នុងលោកយើងនេះ ។

គ្រានោះឯង ចចកករដកៈ និងទមនកៈទាំងពីរ ដែលមានក្ដីស្រេកឃ្លានបៀតបៀនហើយ ទើបប្រឹក្សាគ្នាទៅវិញទៅមក ។ ក្នុងកាលនោះ ចចកទមនកៈ និយាយឡើងថា: "នែសំឡាញ់ដ៏ចំរើន! យើងទាំងពីរនាក់នេះមិនមែនជាប្រធានសម្រេចរាជការផែនទឹកផែនដីទេ បិង្គលកៈនេះស្រឡាញ់រាប់អានសញ្ជីវកៈហើយបោះបង់ការផែនដីខ្លួនចោលអស់ហើយ ពួកសត្វជាបរិពារក៏រត់ចោលអស់ហើយ បើដូច្នេះតើ យើងគិតធ្វើដូចម្ដេច?" ។ ករកដៈឆ្លើយថា: "សំឡាញ់អើយ! បើម្ចាស់យើងមិនធ្វើតាមពាក្យបងទេ បងត្រូវប្រាប់ម្ចាស់យើងទៅ កុំឲ្យមានទោសដល់បងឯង ព្រោះថា:–

១៦០– ព្រះរាជា កាលបើមិនទ្រង់ជ្រាបទេ មន្ត្រីទាំងឡាយគប្បីដាស់តឿនក្រើនរំលឹកឲ្យទ្រង់ជ្រាប ដើម្បីកុំឲ្យមានទោសខុសដល់ខ្លួន ដូចជាបុរោហិតឈ្មោះវិទុរៈ បានដាស់តឿនព្រះបាទអម្ពិកាសុតៈ ។

---

១ ព្រះស្កន្ទកុមារជាបុត្រព្រះឥសូរ ។ ២ នាគបរិតិជាសក្តិព្រះឥសូរ ។

១៦១ – ព្រះរាជាស្រវឹងបុណ្យនឹងដំរីចុះប្រេង តែងដើរខុសផ្លូវ កាលបើដូច្នេះអាមាត្យដែលនៅជិតព្រះអង្គនឹងហ្មដែលរក្សាដំរី ត្រូវគេបន្ទោស ។

អើ! រឿងនេះ បងឯងហើយដែលនាំសញ្ជីវក: ជាសត្វស៊ីស្មៅទៅកាន់សំណាក់ម្ចាស់យើង ដូចជានាំយកភ្លើងទៅដុតដោយដៃខ្លួនឯង" ។ ទមនក: ឆ្លើយតបថា: "សំឡាញ់ រឿងនេះ ពិតមែនដូច្នោះហើយ ទោសនេះជាទោសខ្ញុំមែនហើយ មិនមែនជាទោសម្ចាស់យើងទេ. ព្រោះថា:

១៦២ – ចចកស្លាប់ព្រោះចម្បាំងពពែ ខ្ញុំអន្តរាយព្រោះអាសាឍភូតិ នាងមេអណ្ដើកម្នាក់ កើតទោសពីការងារជនដទៃ ទោសទាំង ៣ នេះកើតពីធ្វើខ្លួនឯង" ។

ករកដ:សួរថា: "ចុះរឿងនោះដូចម្ដេច?" ។ ទមនក:និយាយរៀបរាប់រឿងនោះប្រាប់ថា: –

## ៥– រឿងទេវសម៌:

(ប្រកបរឿងពពែ ២ នឹងចចក, រឿងអ្នកតម្បាញ ជាងកាត់សក់ នឹងការិយា)

នៅក្នុងវិវត្តប្រទេស មានអាស្រមមួយ ជាទីអាស្រ័យនៅនៃបរិព្វាជកម្នាក់ឈ្មោះ ទេវសម៌: ។ បរិព្វាជកនោះបានសន្សំសំពត់ខោអាវល្អៗ ដែលទាយកទាំងឡាយគេជ្រះថ្លាហើយគេបូជាយកមកទុក សន្សំយូរទៅគាត់យកទៅលក់បានប្រាក់កាសច្រើន ។ (មានត)

# សេចក្ដីថ្លែងការ

កាលថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៩៥១ នេះ សមាគមមិត្តសាលាបាលី បានធ្វើមហាសន្និបាតនៅសាលាបាលីជាន់ខ្ពស់ បោះឆ្នោតជ្រើសតាំងក្រុមអភិបាលសម្រាប់ឆ្នាំថ្មី ។ ការបោះឆ្នោតរើសនោះ បានលទ្ធផលដូចតទៅនេះ

លោកកាយ ប៊ុក អធិបតី, លោកកាយ-លុត នឹងលោកមៅ-ម៉ី អធិបតីរង, លោកផេង-ជើរ លេខាធិការ, លោកហេង-យ៉ាន់ នឹង មុិញ-នាគ្រី អនុលេខាធិការ, លោកអ៊ុច-រស់ អគ្គហេរញ្ញិក, លោកតាន់-ប៊ូហេង នឹង ឯល ញ៉ាន់ អនុហេរញ្ញិក, លោកញ៉ុក-ថែម នឹង ចាប-ពិន បណ្ណារក្ស ។

ទីប្រឹក្សាមានចំនួន ១២ រូបគឺ: សម្ដេចព្រះធម្មលិខិតឧត្តមប្រឹក្សា លី-ឯម, សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ជួន-ណាត, សម្ដេចព្រះមហាសុធម្មាធិបតីសង្ឃនាយកគណធម្មយុត្តិ អ៊ុង-ស្រី, ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ព្រះមហាព្រហ្មមុនី ទេព-អ៊ូ ចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ ឯកឧត្តម សម-ញាណ, លោកសម នួន, ឡាំ-ឯម, អ៊ូ-គង់ ឈឹម-ក្រសេម, ម៉ម-ម៉ែម នឹងលោកយឿន-ប៉េម ។

ក្រុមអភិបាលថ្មីបានជ្រើសរើសតាំងគណកម្មការផ្សេងៗតទៅទៀត គឺ:

គណកម្មការសន្និសិទ: ឯកឧត្តមសម - ញាណជាប្រធាន, លោកម៉ៅ ម៉ីអនុប្រធាន, លោកវ៉ែម - ប៉ាន់, ផេង - ជ្រីវ, ម៉ម - យ៉ែម, ស៊ុច - សេ់ ទិន - ហួត នឹងលោកវ៉ា - ស៊ុឃន ជាសមាជិក ។

គណកម្មការទស្សនាវដ្តី: លោកឈឹម - ក្រសេម ជាបណ្ណាធិការ, ព្រះភិក្ខុ ប៉ាង - ខាត់, លោកញូង - សឿង, ប៊ូ - ប៉ូរ, យូរ - អ៊ុន, អ៊ឹម - ភន នឹងលោកទិន - ហួត ជាសមាជិក ។

គណកម្មការអក្សរសាស្ត្រ: លោកវ៉ាយ - ប៊ុក ប្រធាន, លោកអ៊ឹង - ហុងសាត អនុប្រធាន, ព្រះទេពសត្ថា សួរ - ហាយ, ព្រះញាណកោសល ញាណ - ឈឹន, ព្រះបាឡាត់សោភណកោសល ឃិន - ឌុច, លោករឹម - គិន, អ៊ុក - ម៉ូត, ជ័យ ជុំ, ប៊ុន - ថាន់, វ៉ា - ស៊ុឃន នឹងលោកតែ ដុន ជាសមាជិក ។

គណកម្មការបោះពុម្ពសៀវភៅ: លោក ចាប - ពិន ប្រធាន, លោកហេង យ៉ាន់, ស៊ុច - សេ់ នឹងញូង - សឿង សមាជិក ។

IMPRIMERIE ROYALE